ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..............

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុង ជាប់ព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៧៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខនស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញព្រះរាជក្រឹតលេខ៥១៤ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសកិច្ចការព្រំដែន

- បានឃើញអនុក្រឹត្យលេខ៥១៥ អនក្រ-តត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការតែងតាំងសមាសភាពនៃគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនកម្ពុជាជាមួយប្រទេសជិតខាង
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ-បក ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញសេចក្តីសម្រេចលេខ១៧ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ថៃ
- បានឃើញសេចក្តីសម្រេចលេខ១៨ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-ឡាវ
- បានឃើញសេចក្តីសម្រេចលេខ១៩ សសរ ចុះថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា-វៀតណាម
- បានឃើញសេចក្តីសម្រេចលេខ១៤ សសរ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មការចម្រុះខណ្ឌសីមា និងបោះបង្គោលព្រំដែនគោកកម្ពុជា-វៀតណាម
- យោងតាមតម្រូវការចាំបាច់

## សម្រេច

**ប្រការ១** :

ត្រូវបានបង្កើតអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុង ជាប់ព្រំដែនកម្ពុជា ជាមួយប្រទេសជិតខាងចំណុះលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ២** :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១-អភិបាលខេត្ត ក្រុង ជាប់ព្រំដែន | ប្រធាន |
| ២-អភិបាលរងខេត្ត ក្រុង ជាប់ព្រំដែន មួយរូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-មេបញ្ជាការយោធភូមិភាគ នៃបណ្តាខេត្ត ក្រុង ជាប់ព្រំដែន | អនុប្រធាន |
| ៤-នាយខុទ្ទកាល័យខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |
| ៥-ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |
| ៦- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្រុង ជាប់ព្រំដែន | សមាជិក |

៧- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

៨- ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

៩- មេបញ្ជាការប្រតិបត្តិការសឹករងខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១០-មេបញ្ជាការមូលដ្ឋានទ័ពជើងទឹកខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១១-មេបញ្ជាការកងរាជអាវុធហត្ថខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១២-ស្នងការនគរបាលខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៣-អភិបាលស្រុក ខណ្ឌ នៃខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៤-ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនទ្វេរភាគី ច្រកទ្វារតំបន់ព្រំដែននិងច្រកទ្វារព្រំដែនអន្តរជាតិ សមាជិក

១៥-ប្រធានសាខាគយ និងរដ្ឋាករ នៅតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៦-នាយកយនគរបាលអន្តោប្រវេសន៍ នៅតាមច្រកទ្វារព្រំដែនទ្វេរភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារអន្តរជាតិ សមាជិក

១៧-ប្រធានសាខាកាំកុងត្រូល នៅតាមខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

១៨-មេបញ្ជាការកងវរៈការពារព្រំដែន នៃកងយោធពលខេមរភូមិន្ទ ដែលឈរជើងតាមខេត្ត ក្រុងជាប់ព្រំដែន សមាជិក

១៩-នាយនគរបាលជាតិវរៈការពារព្រំដែនគោកនៃស្នងការនគរបាលខេត្ត ក្រុង ជាប់ព្រំដែន សមាជិក

សមាសភាពជាប់ស្តែង នៃអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះត្រូវកំណត់ដោយដីកាសាលាខេត្ត ក្រុង សាមីនីមួយៗ។

**ប្រការ៣** :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ជាជំនួយការឱ្យលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន នៃទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម ៖

១-សម្រួលការងារដល់ក្រុមប្រតិបត្តិការ និងក្រុមបច្ចេកទេសវាស់វែង ដែលចុះបំពេញបេសកម្មក្នុងទឹកដីខេត្ត ក្រុង របស់ខ្លួន ។

២-សម្រួលការងារសាងសង់បង្គោលព្រំដែននៅលើដីជាក់ស្តែង ជាមួយខេត្តជាដៃគូ នៃភាគីម្ខាងទៀត ដោយមានការចូលរួមដឹកនាំបច្ចេកទេសពីអ្នកឯកទេស នៃលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន។

៣-សិក្សា និងលើកគម្រោង ស្តីពីការអភិវឌ្ឍតាមបណ្តោយព្រំដែន ជូនលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

៤-ចូលសហការជាមួយភាគីម្ខាងទៀត ក្នុងការថែរក្សាបង្គោលព្រំដែន ដែលបានបោះរួចហើយលើដីជាក់ស្តែង និងឃ្លាំមើលសភាពការណ៍មិនប្រក្រតីដែលកើតមានឡើង ដូចជា ការផ្លាស់ប្តូទីតាំងបង្គោល ឬបង្គោលព្រំដែន ដែលមានការបែកបាក់ដោយប្រការណាមួយ និងធ្វើរបាយការណ៍មកលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីមានវិធានការចាំបាច់។

៥-ធ្វើរបាយការណ៍មកលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនអំពីគម្រោងអភិវឌ្ឍន៍ភាគីម្ខាងទៀត ដែលមានទីតាំងជាប់នឹងខ្សែព្រំដែន ដើម្បីឱ្យគណៈកម្មាធិការចម្រុះកិច្ចការព្រំដែន មានវិធានការជាមួយភាគីម្ខាងទៀត។

៦-រៀបចំទុកដាក់ និងថែរក្សាឯកសារពាក់ព័ន្ធនឹងព្រំដែន ដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនប្រគល់ជូន។

៧-ប្រមូលព័ត៌មាន ស្តីពីសភាពការណ៍ពាក់ព័ន្ធទៅនឹងការគ្រប់គ្រង ការឆ្លងកាត់ព្រំដែន ដែលកើតឡើងនៅតាមបណ្តោយព្រំដែនក្នុងទឹកដីនៃខេត្ត ក្រុង របស់ខ្លួន ។

៨-អនុវត្តឱ្យបានសម្រេចតាមផែនការ ទិសដៅ និងភារកិច្ច ដែលលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែនប្រគល់ជូន។

៩-ធ្វើរបាយការណ៍តាមដំណាក់កាលនីមួយៗ អំពីសភាពការណ៍ព្រំដែន និងការដោះស្រាយបញ្ហានានានៅតាមព្រំដែនក្នុងទឹកដីខេត្ត ក្រុងរបស់ខ្លួន ការបោះបង្គោលព្រំដែនលើដីជាក់ស្តែង ការឆ្លងកាត់ព្រំដែន ការអភិវឌ្ឍតាមព្រំដែន ជូនប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

**ប្រការ៤** :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានលេខាធិការដ្ឋាន ជាសេនាធិការ ដែលមានទីតាំងនៅក្នុងសាលាខេត្ត ក្រុង នៃបណ្តាខេត្ត ក្រុងជាប់ព្រំដែន ។

លេខាធិការដ្ឋាននេះ មាននាយខុទ្ទកាល័យខេត្ត ក្រុង ជាប្រធាន និងមានមន្ត្រីជំនាញពី ៣នាក់ ទៅ៥នាក់ជាជំនួយការ។

សមាសភាពជាក់ស្តែង នៃប្រធាន និងមន្ត្រីជំនាញ របស់លេខាធិការដ្ឋាននៃអនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវកំណត់ដោយដីកាសាលាខេត្ត ក្រុងសាមីនីមួយៗ ។

**ប្រការ៥** :

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុងសាមី ។

អនុគណៈកម្មាធិការព្រំដែនខេត្ត ក្រុងនេះ ត្រូវប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ៦** :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវជានិរាករណ៍ ។

**ប្រការ៧** :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលខេត្ត ក្រុង ដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពដូចមានចែងក្នុងប្រការ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ តុលា ឆ្នាំ២០០៧

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-ដូចប្រការ៧
-ឯកសារ កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**